ក

មាតិកា

I-រាជរដ្ឋាភិបាល

អនុក្រឹត្យ

០៨-១១-២០០២ - អនុក្រឹត្យលេខ ៥២១ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៣១៧៣

០៨-១១-២០០២ - អនុក្រឹត្យលេខ ៥២២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣១៧៤

០៨-១១-២០០២ - អនុក្រឹត្យលេខ ៥២៣ អនក្រ.តត ស្តីពីការជូនមេដាយសសាបនាជាតិ ៣១៧៥

០៨-១១-២០០២ - អនុក្រឹត្យលេខ ៥២៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៧៦

០៨-១១-២០០២ - អនុក្រឹត្យលេខ ៥២៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៧៧

០៨-១១-២០០២ - អនុក្រឹត្យលេខ ៥២៦ អនក្រ.តត ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល ប្រចាំចំការកៅស៊ូ សំរាប់អាណត្តិទី ២ ៣១៧៨

II- ការខារបណ្ណាក្រសួង

១-ធីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៨-១១-២០០២ - ប្រកាសលេខ៦៩១ ឧរថ.ឧតស .ប្រក ស្តីពីការអនុញ្ញាតឱ្យអ្នកស្រី **ស៊ីម លី** ជនជាតិខ្មែរ បន្តដំណើការផលិត ទឹកស៊ីអ៊ីវ ទឹកម្ទេស ទឹកសៀង និងទឹកខ្មេះ នៅក្នុងទីតាំងផ្ទះសង់ថ្មី ផ្លូវជាតិលេខ២ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ៣១៨១

០៨-១១-២០០២ - ប្រកាសលេខ ៦៩២ ឧរថ.ឧតស .ប្រក ស្តីពីការអនុញ្ញាតឱ្យលោក **តែម សុខ** ជនជាតិខ្មែរ បន្តដំណើការឡផលិត ឥដ្ឋ -ក្បឿង នៅក្នុងទីតាំងផ្ទះគ្មានលេខ ភូមិស្វាយប៉ាក ខ័ណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ៣១៨២

០៨-១១-២០០២ - ប្រកាសលេខ ៦៩៣ ឧរថ.ឧតស .ប្រក ស្តីពីការអនុញ្ញាតឱ្យលោក **ខេង គង់** ជនជាតិខ្មែរ បន្តដំណើការឧស្សាហកម្មតូចផលិតដែកគោល និង លួសបន្លា " **ផែនដី** " នៅក្នុងទីតាំងផ្ទះលេខ១០E ផ្លូវលេខ ៣៥៩ ភូមិដើមអំពិល សង្កាត់ច្បារអំពៅទី១ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ៣១៨៣

០៨-១១-២០០២ - ប្រកាសលេខ ៦៩៤ ឧរថ.ឧតស .ប្រក ស្តីពីការអនុញ្ញាតឱ្យលោក **វង្វៀត សៅរិទ្ធី** ជនជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ន ភូមិសំប៉ានក្រោម ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល បន្តដំណើការឧស្សាហកម្មតូចផលិតទឹកកកដើម នៅក្នុងទីតាំងដូចខាងលើ ៣១៨៤

០៨-១១-២០០២ - ប្រកាសលេខ ៦៩៥ ឧរថ.ឧតស .ប្រក ស្តីពីការអនុញ្ញាតឱ្យលោក **តេម ផល** ជនជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ន ភូមិខ្ពបក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល បន្តដំណើការ ឧស្សាហកម្មតូចផលិតទឹកកកដើម នៅក្នុងទីតាំងដូចខាងលើ ៣១៨៥

០៨-១១-២០០២ - ប្រកាសលេខ ៦៩៦ ឧរថ.ឧតស .ប្រក ស្តីពីការអនុញ្ញាតឱ្យអ្នកស្រី **ឡាយ ទូចលី** ជនជាតិខ្មែរ បន្តដំណើការរោងម៉ាស៊ីនកិនស្រូវកម្លាំង ៨០ សេះ នៅក្នុងទីតាំងភូមិផ្សារលើ ឃុំលលកស ស្រុកសំពៅមាស ខេត្តពោធិសាត់ ៣១៨៦

០៨-១១-២០០២ - ប្រកាសលេខ៦៩៧ ឧរថ.ឧតស.ប្រក ស្តីពីការអនុញ្ញាតឱ្យលោក **ម៉ីន ឡារិន** ជនជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ន ភូមិខ្ពបក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល បន្តដំណើការ ឧស្សាហកម្មតូចផលិតទឹកកកដើម នៅក្នុងទីតាំងដូចខាងលើ ៣១៨៧

០៨-១១-២០០២ - ប្រកាសលេខ ៦៩៨ ឧរថ.ឧតស .ប្រក ស្តីពីការអនុញ្ញាតឱ្យលោក **ផាត់ ផន** ជនជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ន ភូមិថ្នល់បត់ ឃុំឬស្សីក្រាំង ស្រុកមោងឬស្សី ខេត្តបាត់ដំបង បន្តដំណើការរោងម៉ាស៊ីនកិនស្រូវកម្លាំង ១២០ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ៣១៨៨

០៨-១១-២០០២ - ប្រកាសលេខ ៦៩៩ ឧរថ.ឧតស .ប្រក ស្តីពីការអនុញ្ញាតឱ្យលោក **ខា ឡេង** ជនជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៩៧០ បេ ផ្លូវកម្ពុជាក្រោម សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ បន្តដំណើការសិប្បកម្មផលិតស្រាកែច្នៃ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ៣១៨៩

០៨-១១-២០០២ -ប្រកាសលេខ ៧០០ ឧរថ.ឧតស .ប្រក ស្តីពីការអនុញ្ញាតឱ្យអ្នកស្រី **ឈាង ទូចស៊ីម** ជនជាតិខ្មែរអាស័យដ្ឋានបច្ចុប្បន្ន មណ្ឌលបឹងវែង សង្កាត់វាលរិញ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ បន្តដំណើការផលិត ទឹកស៊ីអ៊ីវ និង ទឹកម្ទេស " **ហេង ស៊ីម**" នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ៣១៩០

០៨-១១-២០០២ -ប្រកាសលេខ ៧០១ ឧរថ.ឧតស .ប្រក ស្តីពីការអនុញ្ញាតឱ្យអ្នកស្រី **ស្រ៊ី គីមស្រួយ** ជនជាតិខ្មែរអាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៣ ភូមិប្រឡាយធំ ឃុំព្រៃញី ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ បន្តដំណើការផលិត សៀងនៅក្នុង ទីតាំង ដូចអាស័យដ្ឋានខាងលើ ៣១៩១

០៨-១១-២០០២ - ប្រកាសលេខ ៧០២ ឧរថ.ឧតស .ប្រក ស្តីពីការអនុញ្ញាតឱ្យលោក **ខា ម៉ី** ជនជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ន ភូមិអន្លង់សាន្ត ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល បន្តដំណើការរោងម៉ាស៊ីនកិនស្រូវកម្លាំង ២៤ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ៣១៩២

០៨-១១-២០០២ - ប្រកាសលេខ ៧០៣ ឧរថ.ឧតស .ប្រក ស្តីពីការអនុញ្ញាតឱ្យលោក **ឆាន់ សាំងហ៊ុន** ជនជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ន ភូមិក្រូចឆ្មារក្រោម ឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម បន្តដំណើការសិប្បកម្មផលិតបារី នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ៣១៩៣

០៨-១១-២០០២	- ប្រកាសលេខ ៧០៤ ឧរថ.ឧតស .ប្រក ស្តីពីការអនុញ្ញាតឱ្យលោក **អ៊ុត ទៃ** ជនជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ន ភូមិអន្លង់វិល ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង បន្ត ដំណើរការឡផលិតឥដ្ឋ - ក្បឿង នៅក្នុងទីតាំង ភូមិព្រៃតែក ឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង	៣១៩៤
០៨-១១-២០០២	- ប្រកាសលេខ ៧០៥ ឧរថ.ឧតស .ប្រក ស្តីពីការអនុញ្ញាតឱ្យលោក **តែ គា** ជនជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ន ដីឡូតិ៍គ្មានលេខ ផ្លូវលេខ ១០១៩ ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ បើកដំណើរការ សិប្បកម្ម កែច្នៃស្រា នៅក្នុង ទីតាំងដូច អាស័យដ្ឋានខាងលើ	៣១៩៥
០៨-១១-២០០២	- ប្រកាសលេខ ៧០៦ ឧរថ.ឧតស .ប្រក ស្តីពីការអនុញ្ញាតឱ្យលោក **កែវ រិទ្ធី** ជនជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៧ ភូមិពាលញែក ១ ឃុំ ផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិសាត់ បន្តដំណើរការ ឧស្សាហកម្មតូច ផលិតទឹកកកដើម នៅក្នុង ទីតាំងដូច អាស័យដ្ឋានខាងលើ	៣១៩៦
០៨-១១-២០០២	- ប្រកាសលេខ ៧០៧ ឧរថ.ឧតស .ប្រក ស្តីពីការអនុញ្ញាតឱ្យលោក **ស៊្រុន ឈាងគ្រួយ** ជនជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ១ ភូមិប្រឡាយធំ ឃុំ ព្រៃញី ស្រុកសំពៅមាស ខេត្តពោធិសាត់ បន្តដំណើរការ ឧស្សាហកម្មតូច ផលិតទឹកកកដើម នៅក្នុង ទីតាំងដូច អាស័យដ្ឋានខាងលើ	៣១៩៧
០៨-១១-២០០២	- ប្រកាសលេខ ៧០៨ ឧរថ.ឧតស .ប្រក ស្តីពីការអនុញ្ញាតឱ្យលោក **ហៀង សុផល** ជនជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ១ ភូមិពោធិជំណាក់ ឃុំ វាល ស្រុកកណ្តៀង ខេត្តពោធិសាត់ បន្តដំណើរការ ឧស្សាហកម្ម តូច ផលិតទឹកកកដើម នៅក្នុង ទីតាំងដូច អាស័យដ្ឋានខាងលើ	៣១៩៨
០៨-១១-២០០២	- ប្រកាសលេខ ៧០៩ឧរថ.ឧតស.ប្រក ស្តីពីការអនុញ្ញាតឱ្យលោក **ឈឹម ចារទ** ជនជាតិខ្មែរអាស័យដ្ឋានបច្ចុប្បន្ន ភូមិស្ពានថ្ម ឃុំរលាប ស្រុកសំពៅមាស ខេត្តពោធិសាត់ បន្តដំណើរការសិប្បកម្មផលិតនំថ្លែម "**រូបសេះលោះ**" នៅក្នុង ទីតាំងដូច អាស័យដ្ឋាន ខាងលើ	៣១៩៩
០៨-១១-២០០២	- ប្រកាសលេខ ៧១០ ឧរថ.ឧតស.ប្រក ស្តីពីការអនុញ្ញាតឱ្យលោក **ខា ឃុន** ជនជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ន ភូមិស្ពានថ្ម ឃុំ រលាប ស្រុកសំពៅមាស ខេត្តពោធិសាត់ បន្តដំណើរការ សិប្បកម្ម ផលិតនំថ្លែម "**រូបត្រាច**" នៅក្នុង ទីតាំងដូច អាស័យដ្ឋាន ខាងលើ	៣២០០

២-ទីស្តីការក្រសួងមន្ត្រីក្រសួងព័ត៌មាន

០៧-១១-២០០២	- ប្រកាសលេខ ២៧៩/០២ ព.ម .ប្រក ស្តីពីការអនុញ្ញាតឱ្យអ្នកស្រី **ឃុន អេឡេណា** បន្តបើកស្ថានីយ៍ទូរទស្សន៍ខ្មែរប៉ុស្តិ៍លេខ ៩ និងស្ថានីយ៍វិទ្យុ FM ១០៧ MHz	៣២០១

០៧-១១-២០០២	- ប្រកាសលេខ ២៨០/០២ ព.ម .ប្រក ស្តីពីការអនុញ្ញាតឱ្យលោក **ហ៊ី បូរិន** ស្ថិតនៅភូមិអូរអំបិល ឃុំអូរអំបិល ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ បើកស្ថានីយ៍ទូរទស្សន៍ខ្សែកាប សំរាប់បន្តជាវអោយអតិថិជននៅ ឃុំបឹងរាំងស្រុកកំរៀង ខេត្តបាត់ដំបង	៣២០២
០៧-១១-២០០២	- ប្រកាសលេខ ២៨១/០២ ព.ម .ប្រក ស្តីពីការអនុញ្ញាតឱ្យលោក **លិន សុខហេង** ស្ថិតនៅ ភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ បើកស្ថានីយ៍ ទូរទស្សន៍ខ្សែកាប សំរាប់បន្តជាវអោយអតិថិជននៅ ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង	៣២០៣

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

២៩-១០-២០០២	- ប្រកាសលេខ ២៦៧១ ប្រ.ក ស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍ព្រំដែន	៣២០៤

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៥៧១ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងទេសចរណ៍

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនដល់ឥស្សរជនបរទេស ០២ រូប ដែលមានគុណបំណាច់ខ្ពស់ និង ស្នាដៃល្អ ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ លើវិស័យទេសចរណ៍ នៅព្រះរាជាណាចក្រកម្ពុជា អោយមានការរីកចំរើន ដូចមានរាយនាមខាងក្រោម ÷

១-លោក Richard Helfer ប្រធាន និង ជានាយកប្រតិបត្តិនៃក្រុមហ៊ុន Raffles Holdings Limited និង Raffles International Limited

២-លោក José Carreras សិល្បករ

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងទេសចរណ៍ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា　　**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៥២២ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

ស ម្រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនលោកបណ្ឌិត **សឺរ៉ន្ធ សុខ្ញ** តំណាងក្រុមបញ្ញវន្តខ្មែរនៅប្រទេសបារាំង ដែលបានធ្វើអំណោយជាឯកសារវិទ្យាសាស្ត្រចំនួន ៥៥ កេស មានតំលៃជាទឹកប្រាក់ចំនួន ២០០.០០០ USD សំរាប់ដាក់ក្នុងបណ្ណាល័យសម្តេច ហ៊ុន សែន នាសកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥២៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឧកញ៉ា **តែង ឡា** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយស្ថាបនាផ្លូវលំ ០២ ខ្សែ មានប្រវែង ៦.៦០០ ម៉ែត្រ រួមទាំងស្ពាន ០៣ កន្លែង និង លូកាត់ផ្លូវ ០៤ កន្លែង នៅឃុំតាអូរ ស្រុកគីរីវង្ស ខេត្តតាកែវ ចំណាយអស់ទឹកប្រាក់ចំនួន ៤៣.៥៤៧ USD ។

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៥៧៤...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

ស ម្រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយថ្នាក់ស្ថាបនាជាតិ** ជូនលោក **ឈឹម សាខន** ស្នងការរងនគរបាលខេត្តព្រៃវែង ដែលបានបរិច្ចាគថវិកា ៥.៧៨៩ USD ចូលរួមជួយកសាងព្រះវិហារ វត្តឧទុម្ពរ ហៅវត្តល្វាក្រោម ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល ។

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវ អនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥២៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសិរីវឌ្ឍស្ថាបនាជាតិ** ជូនឯកឧត្តម **ស៊ូ គឹមស៊ុន** ដែលបានបរិច្ចាគថវិកាចំនួន ៤.២៥០ USD សំរាប់ទិញស៊ីម៉ង់ និង ដែក ជួយកសាងព្រះវិហារ វត្តឧទុម្ពរ ហៅ វត្តល្វាក្រោម ក្នុងឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល ។

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៧៦ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល ប្រចាំចំការកៅស៊ូ សំរាប់អាណត្តិទី២

* * *

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស / ៩៤ / ០២ / ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ ១៣.១៤.១៥.១៦.១៧.១៨ និង ១៩ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតចំការកៅស៊ូមេមត់ ចំការកៅស៊ូជុប ចំការកៅស៊ូក្រែក ចំការកៅស៊ូពាមជាំង ចំការកៅស៊ូបឹងកេត ចំការកៅស៊ូចំការអណ្តូង និងចំការកៅស៊ូស្នួល ជាគ្រឹះស្ថានសាធារណៈ មានលក្ខណៈសេដ្ឋកិច្ច
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូទាំង ៧ ដែលជាគ្រឹះស្ថានសាធារណៈ មានលក្ខណៈសេដ្ឋកិច្ច សំរាប់អាណត្តិទី២ មានរាយនាមដូចខាងក្រោម :-

ក- សមាសភាពក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូមេមត់ :

១-	លោក	ណា	ម៉ារ៉ាឌី	ប្រធានអគ្គនាយកចំការកៅស៊ូមេមត់	ប្រធាន
២-	លោក	ឌួខ	ម៉ុនធី	តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
៣-	លោក	កែវ	មិថិត្រ	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក

៤- លោក ឯក ទីរះដេដ្ឋ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៥- លោក ម៉ក សារេន តំណាងសាលាខេត្តកំពង់ចាម សមាជិក
៦- លោក ជីម ខូន តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ សមាជិក
៧- លោក ឃុត សុផៃ តំណាងនិយោជិតរបស់ចំការកៅស៊ូមេមត់ សមាជិកស្វ័យប្រវត្តិ

ខ- សមាសភាពក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូជុប :

១- លោក ម៉ក់ គឹមហុង ប្រធានអគ្គនាយកចំការកៅស៊ូជុប ប្រធាន
២- លោក ទឹម ចិន្តា តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
៣- លោកជំទាវ ស៊ុំ ដេហ៊្វីន តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិកា
៤- លោក គវ៉ង លាងចំណុះ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៥- លោក យិន ម៉ុនឆិត តំណាងសាលាខេត្តកំពង់ចាម សមាជិក
៦- លោក អៀង ស៊ីថា តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ សមាជិក
៧- លោក សុក សារ៉ម តំណាងនិយោជិតរបស់ចំការកៅស៊ូជុប សមាជិកស្វ័យប្រវត្តិ

គ- សមាសភាពក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូក្រែក :

១- លោក សៀក ពិសិដ្ឋ ប្រធានអគ្គនាយកចំការកៅស៊ូក្រែក ប្រធាន
២- លោក ចាយ សាគុណ តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
៣- លោកស្រី ណី សុឃីម តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិកា
៤- លោក សាន់ សារ៉េរ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៥- លោក លន់ លីមថៃ តំណាងសាលាខេត្តកំពង់ចាម សមាជិក
៦- លោក ស្វាយ ចន្ទ្រនា តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ សមាជិក
៧- លោក ឆេស ឌុំ តំណាងនិយោជិតរបស់ចំការកៅស៊ូក្រែក សមាជិកស្វ័យប្រវត្តិ

ឃ- សមាសភាពក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូពាមជាំង :

១- លោក ម៉ែន ស៊ីផាន់ ប្រធានអគ្គនាយកចំការកៅស៊ូពាមជាំង ប្រធាន
២- លោក កៅ ផុងហួ តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
៣- លោក ឡុង សុខា តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
៤- លោក យិនន៍ តាំយឈន់ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៥- លោក សូ ស៊ុំគៀន តំណាងសាលាខេត្តកំពង់ចាម សមាជិក
៦- លោក គង់ សេរី តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ សមាជិក
៧- លោក ត្រី ឈុនឡេង តំណាងនិយោជិតរបស់ចំការកៅស៊ូពាមជាំង សមាជិកស្វ័យប្រវត្តិ

ង- សមាសភាពក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូបឹងកេត :

១- លោក ស៊ុំ ចណ្ណារ៉ា ប្រធានអគ្គនាយកចំការកៅស៊ូបឹងកេត ប្រធាន
២- លោក ញ៉ិប ច័ន្ទថេត តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
៣- លោក អ៊ុំ សម្បូណ៌ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
៤- លោក ម៉ម និច តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៥- លោក	នួន	ម៉ូលីន	តំណាងសាលាខេត្តកំពង់ចាម	សមាជិក
៦- លោក	ផេង	មុន្នាទី	តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ	សមាជិក
៧- លោក	ជួន	គីមឡាយ	តំណាងនិយោជិតរបស់ចំការកៅស៊ូបឹងកេត	សមាជិកស្ម័គ្រប្រវត្តិ

ច- សមាសភាពក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូចំការអណ្តូង :

១- លោក	លឹម	ស៊ុនលាង	ប្រធានអគ្គនាយកចំការកៅស៊ូចំការអណ្តូង	ប្រធាន
២- លោក	ផាត់	លេង	តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
៣- លោក	អ៊ុច	ខេង	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៤- លោក	ម៉ុង	ស៊ីម	តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៥- លោក	ខួត	ផន	តំណាងសាលាខេត្តកំពង់ចាម	សមាជិក
៦- លោក	សៅ	សេរីមុនី	តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ	សមាជិក
៧- លោក	យុន	ស៊ុនលី	តំណាងនិយោជិតរបស់ចំការកៅស៊ូចំការអណ្តូង	សមាជិកស្ម័គ្រប្រវត្តិ

ឆ- សមាសភាពក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូស្នួល :

១- លោក	ម៉ិច	សុវណ្ណ	ប្រធានអគ្គនាយកចំការកៅស៊ូស្នួល	ប្រធាន
២- លោក	ស៊ឹម	ហង្ស	តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
៣- លោក	នូ	រិទ្ធី	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៤- លោក	ស៊ុន	គីមស្រ៊ុន	តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៥- លោកស្រី	ត្រឹង	ថាវី	តំណាងសាលាខេត្តក្រចេះ	សមាជិកា
៦- លោក	ម៉ូ	ចាន់សុខ	តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ	សមាជិក
៧- លោក	ឯក	សុវណ្ណ	តំណាងនិយោជិតរបស់ចំការកៅស៊ូស្នួល	សមាជិកស្ម័គ្រប្រវត្តិ

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០២

ហ៊ុន សែន

កន្លែងទទួល :-

- ខុទ្ទកាល័យ ព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

N°៩៤១ ឧ.រ.ថ/ប្រក.ស.ប.ក — រាជធានីភ្នំពេញ,ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០២

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៣៥៥ ឧក.ប្រក ចុះថ្ងៃទី ២៤-៣-៩៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំបន្តដំណើរការសិប្បកម្មផលិតទឹកស៊ីអ៊ីវ ទឹកម្ទេស ទឹកសៀង និង ទឹកខ្មេះ របស់អ្នកស្រី ស៊ីវ លី ចុះថ្ងៃទី ០៦-៥-០២ ។

សំរេច

ប្រការ១:- អនុញ្ញាតអោយអ្នកស្រី **ស៊ីវ លី** ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ២២៥៧៦៩ ភ.ព ចុះថ្ងៃទី ២២-៤-៨៩ អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១២៨E₀ ផ្លូវលេខ ១៩ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិត ទឹកស៊ីអ៊ីវ ទឹកម្ទេស ទឹកសៀង និង ទឹកខ្មេះ នៅក្នុងទីតាំង ផ្ទះសង់ថ្មី ផ្លូវជាតិលេខ២ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ២:- អ្នកស្រី **ស៊ីវ លី** ត្រូវមកចុះបញ្ជីផលិតផល និង យកគំរូផលិតផលនៃឡូត៍ផលិតផលនីមួយៗរបស់ខ្លួនមកពិនិត្យគុណភាពនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល មុននឹងចរាចរនៅលើទីផ្សារ ។

ប្រការ៣:- ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្ករអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ៤:- អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង អ្នកស្រី **ស៊ីវ លី** ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ៥:- ប្រកាសនេះមានអនុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចំលងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុង ភ្នំពេញ
- ខណ្ឌ មានជ័យ "ដើម្បីជ្រាប"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ស៊ុយ_សែម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៦៩៧ ឧរថ ឧកសា-ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០០២

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៥៨៦ ឧក.ប្រក ចុះថ្ងៃទី ២១-១០-៩៨ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បន្តដំណើរការឡផលិតឥដ្ឋ-ក្បឿង របស់លោក កែវ សុខ ចុះថ្ងៃទី ២៣-៩-០២ ។

សម្រេច

ប្រការ១: អនុញ្ញាតអោយលោក កែវ សុខ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ៣០៦១៣៦ ភ.ព ចុះថ្ងៃទី ១៥-១០-៩១ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ៦ឃ ផ្លូវលេខ២៧៨ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការឡផលិតឥដ្ឋ-ក្បឿង នៅក្នុងទីតាំង ផ្ទះគ្មានលេខ ភូមិស្វាយប៉ាក សង្កាត់ស្វាយប៉ាក ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ២: ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ៣: អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង លោក កែវ សុខ ត្រូវទទួលអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ៤: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចំលងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុង ភ្នំពេញ
- ខណ្ឌ ឫស្សីកែវ

  "ដើម្បីជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ស៊ុយ សែម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry , Mines and Energy

N° ៦៩៣ ឧ.ស.ថ.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ ២០០២

ប្រកាស
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៩អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៦៧៦ ផក.ប្រក ចុះថ្ងៃទី ១៤-៧-៩៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បន្តដំណើរការឧស្សាហកម្មតូចផលិតដែកគោល និង លួសបន្លា"ផែនដី" របស់លោក ខេង គង់ ចុះថ្ងៃទី ១៧-១០-០២ ។

សំរេច

ប្រការ១:- អនុញ្ញាតអោយលោក ខេង គង់ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ១២២៩៨៣ ភ.ព ចុះថ្ងៃទី ០១-៦-៨២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ៩៣៣ ផ្លូវជាតិលេខ៥ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ បន្តដំណើរការឧស្សាហកម្មតូចផលិតដែកគោល និង លួសបន្លា "ផែនដី" នៅក្នុងទីតាំង ផ្ទះលេខ១០E ផ្លូវលេខ៣៥៩ ភូមិដើមអំពិល សង្កាត់ច្បារអំពៅទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ២:- ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ៣:- អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង លោក ខេង គង់ ត្រូវទទួលអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ៤:- ប្រកាសនេះមានអនុភាពតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចំលងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុង ភ្នំពេញ
- ខ័ណ្ឌ មានជ័យ
  "ដើម្បីជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ស៊ុយ សែម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

No ៦៩៤ ឧស្សាហ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០២

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៦៧៩ ឧក.ប្រក ចុះថ្ងៃទី ១៤-៧-៩៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម របស់លោក ទ្រៀក សៀកទ្រី ចុះថ្ងៃទី ០២-១០-០២ ។

សំរេច

ប្រការ១: អនុញ្ញាតអោយលោក ទ្រៀក សៀកទ្រី ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ២៦៦១៨៣ក.ណ ចុះថ្ងៃទី ២៧-៥-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិសំពាន់ក្រោម ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ២: ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

ប្រការ៣: អគ្គនាយកឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និង លោក ទ្រៀក សៀកទ្រី ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ៤: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ស៊ុយ សែ

ចំលងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្ត កណ្តាល
- សាលាស្រុក ស្អាង
  "ដើម្បីជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N°៦៩៥ ឧរម ឧកស.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ២០០២

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្ដេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្ដីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៧៥អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៥៣៩ ឧក.ប្រក ចុះថ្ងៃទី ០៨-៦-៩៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម របស់លោក គេម ផល ចុះថ្ងៃទី ១៩-៩-០២ ។

សំរេច

ប្រការ១:- អនុញ្ញាតអោយលោក គេម ផល ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ២៧៦៩៧០ ក.ណ ចុះថ្ងៃទី ២០-៦-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ខ្ពបក្រោម ឃុំ ខ្ពប ស្រុក ស្អាង ខេត្ត កណ្ដាល បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ២:- ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

ប្រការ៣:- អគ្គនាយកឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្ដាល និង លោក គេម ផល ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ៤:- ប្រកាសនេះមានអនុភាពអនុវត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចំលងជូន:
- -ទីស្ដីការគណៈរដ្ឋមន្ត្រី
- -រាជកិច្ច
- -ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -សាលាខេត្ត កណ្ដាល
- -សាលាស្រុក ស្អាង

"ដើម្បីជ្រាប"
- -ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

សុយ សែម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

N°៦៩៦ ឧស៊ីធុនស-ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ២០០២

<u>ប្រកាស</u>

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ឆស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៩០៤ ឧក.ប្រក ចុះថ្ងៃទី ១៣-១០-៩៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ របស់អ្នកស្រី **ឡាយ ទូចស៊ីម** ចុះថ្ងៃទី ២៣-៩-០២ ។

<u>សំរេច</u>

<u>**ប្រការ១:**</u>- អនុញ្ញាតអោយអ្នកស្រី **ឡាយ ទូចស៊ីម** ជនជាតិខ្មែរ កាន់លិខិតបញ្ជាក់លេខ ៣៥៣/៩លស ចុះថ្ងៃទី ០២-៩-៩៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ពោធិតាគួយ ឃុំ លលកស ស្រុក សំពៅមាស ខេត្ត ពោធិសាត់ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០សេះ នៅក្នុងទីតាំង ភូមិ ផ្សារឈើ ឃុំ លលកស ស្រុក សំពៅមាស ខេត្ត ពោធិសាត់ ។

<u>**ប្រការ២:**</u>- អ្នកស្រី **ឡាយ ទូចស៊ីម** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

<u>**ប្រការ៣:**</u>- ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

<u>**ប្រការ៤:**</u>- អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្ត ពោធិសាត់ និង អ្នកស្រី **ឡាយ ទូចស៊ីម** ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

<u>**ប្រការ៥:**</u>- ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

<u>ចំលងជូន:</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្ត ពោធិសាត់
- សាលាស្រុក សំពៅមាស

"ដើម្បីជ្រាប"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

សួយ សែម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N°៦៩៧ ឧ.ប.ឧ.ស.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០០២

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៦៤៤ ឧក.ប្រក ចុះថ្ងៃទី ២៦-៦-៩៧ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម របស់លោក ម៉ិន ឡាំង ចុះថ្ងៃទី ១៩-៩-០២ ។

សំរេច

ប្រការ១:- អនុញ្ញាតអោយលោក ម៉ិន ឡាំង ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ២៧៦២៤២ក.ណ ចុះថ្ងៃទី១៧-៦-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ខ្ពបក្រោម ឃុំ ខ្ពប ស្រុក ស្អាង ខេត្ត កណ្តាល បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម នៅក្នុងទីតាំង ដូចអាស័យដ្ឋាន ខាងលើ ។

ប្រការ២:- ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

ប្រការ៣:- អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្ត កណ្តាល និង លោក ម៉ិន ឡាំង ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ៤:- ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ស៊ុយ សែម

ចំលងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្ត កណ្តាល
- សាលាស្រុក ស្អាង
  "ដើម្បីជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N°៦៩៨ ឧបរទស-ប្រក

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០២

ប្រកាស
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៧៨១ ឧក.ប្រក ចុះថ្ងៃទី ១៣-៩-៩៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ របស់លោក ផាត់ ផន ចុះថ្ងៃទី ២៣-៩-០២ ។

សម្រេច

<u>ប្រការ១:</u>- អនុញ្ញាតអោយលោក ផាត់ ផន ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ១០៨៩៧៥ប.ប ចុះថ្ងៃទី២២-៧-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ផ្លូវបត់ ឃុំ ឫស្សីក្រាំង ស្រុក មោងឫស្សី ខេត្ត បាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

<u>ប្រការ២:</u>- លោក ផាត់ ផន ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករ លេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

<u>ប្រការ៣:</u>- ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

<u>ប្រការ៤:</u>- អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្ត បាត់ដំបង និង លោក ផាត់ ផន ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

<u>ប្រការ៥:</u>- ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

<u>ចំលងជូន:</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្ត បាត់ដំបង
- សាលាស្រុក មោងឫស្សី
"ដើម្បីជ្រាប"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ស៊ុយ_សែម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

№ ៦៩៩ ឧរប.ឧកស-ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០០២

ប្រកាស
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៩១៦ ផក.ប្រក ចុះថ្ងៃទី ២០-១០-៩៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បន្តដំណើរការសិប្បកម្មផលិតស្រាកែច្នៃ " ហ៊ុយ ឈុន " របស់លោក ជា ទ្រា ចុះថ្ងៃទី ០៩-១០-០២ ។

សំរេច

<u>ប្រការ១:</u>- អនុញ្ញាតអោយលោក ជា ទ្រា ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ៣១១៧៦១ ភ.ព ចុះថ្ងៃទី ២៧-៥-៩១ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៩៧០បេ ផ្លូវកម្ពុជាក្រោម សង្កាត់ ទឹកល្អក់ទី១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតស្រាកែច្នៃ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

